ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

# សាលក្រមព្រហ្មទណ្ឌ

តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ÷ ៧៤៩ អ.ក

ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០

សាលក្រមលេខ÷ ១០៧ (ខ)

ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល

នាថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោងពីរ និងសាមសិបនាទីរសៀល និងប្រកាសសាលក្រម

នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ដែលមានសមាសភាពដូចតទៅ÷

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្ដាល

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ៧៤៩ អ.ក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ មានជនជាប់ចោទ÷

១. ឈ្មោះ[redacted] លាង ភេទប្រុស អាយុ៥៦ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កសិករ មានទីកន្លែងកំណើតនៅ[redacted] ខេត្តកណ្ដាល មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ[redacted] អី (រស់) ម្ដាយឈ្មោះ[redacted] ហ៊ីង (រស់) ប្រពន្ធឈ្មោះ [redacted] អាត (រស់) មានកូន០៤នាក់ ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

២. ឈ្មោះ[redacted] អាត ភេទស្រី អាយុ៥៤ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កសិករ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកណ្ដាល និងមានទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ[redacted] ហាន (រស់) ម្ដាយឈ្មោះ[redacted] ណាយ (រស់) ប្ដីឈ្មោះ[redacted] លាង (រស់) មានកូន០៤នាក់ ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

៣. ឈ្មោះ [redacted] សេងទ្រី ភេទប្រុស កើតឆ្នាំ១៩៦៦ (អាយុ៥៤ឆ្នាំ) ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ នៅផ្ទះ (ពិការ) ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកណ្តាល និងមានទីលំនៅ[redacted]ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ចេប (ស្លាប់) ម្តាយឈ្មោះ[redacted]សុទ្ធ (ស្លាប់) ប្រពន្ធឈ្មោះ [redacted]រីម (រស់) មានកូន០៤នាក់ ជានីតិជនទោសពីមុនគ្មាន។ (ក្រៅឃុំ)

ត្រូវជាប់ចោទពីបទ÷ ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន និងប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅភូមិអំពៅព្រៃ ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា ២៥៣ និងមាត្រា២៥៥ នៃច្បាប់ភូមិបាល និងមាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ ។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ចេប សេងទ្រី ។

**ដើមបណ្តឹងរដ្ឋប្បវេណី÷**

**១.ឈ្មោះ** [redacted] **វ៉ាន់ឌី** ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ នគរបាល ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅ [redacted]ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ហាក់សេង (ស្លាប់) ម្តាយឈ្មោះ [redacted] ស្រ (រស់) ប្រពន្ធឈ្មោះ [redacted] សុខឃាន (រស់) មានកូន០៣នាក់ ជានីតិជន ។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

-បានឃើញ ដីកាដំណោះស្រាយលេខ÷១៣១១ ដក.ជស/២១ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះបន្តលេខ÷ ០១៣ ដកចត/២២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

## អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ ÷

កាលពីអំឡុងឆ្នាំ២០២០ មានករណី ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន និងប្រើប្រាស់ឯកសារសាធារណៈក្លែង កើតឡើងនៅចំណុចភូមិអំពៅព្រៃ ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បង្កឡើងដោយឈ្មោះ[redacted] លាង និងប្រពន្ធឈ្មោះ [redacted] អាត បានលួចលក់ដីមួយកន្លែង មានទំហំ ៨,៥៨៦ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិអំពៅព្រៃ



Scanned with CamScanner

(អតីតភូមិពោកម៉ា) ឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល បច្ចុប្បន្នកាត់ចូលមកភូមិទួលក្រសាំង សង្កាត់រការខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្ដាល ជាកម្មសិទ្ធិរបស់ជនរងគ្រោះឈ្មោះ [redacted] វ៉ាន់នី ភេទប្រុស អាយុ៤៧ឆ្នាំ យោងលិខិតលក់ទិញដីលេខ: ០៧/៩៧ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៧ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៣៥៥/១៥ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ទៅឱ្យជនជាប់ចោទឈ្មោះ [redacted] សេងទ្រី តាមរយៈកិច្ចសន្យាលក់ផ្ដាច់ដីផ្ទះលេខ ០៤/០៥ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៥ ដែលជាឯកសារក្លែងបន្លំ។ មិនតែប៉ុណ្ណោះ ជនជាប់ចោទខាងលើ រួមទាំងបក្សពួកបានចូលទៅកាន់កាប់ កាប់ឆ្ការផលដំណាំលើដីរបស់ជនរងគ្រោះទាំងបំពាន រហូតដល់សមត្ថកិច្ចចុះទៅហាមឃាត់ទើបបញ្ឈប់សកម្មភាពនេះ ហើយជនជាប់ចោទ ក៏បានឆ្លើយថានៅដំណាក់កាលអយ្យការថា ពួកខ្លួនពិតជាបានចូលទៅកាន់កាប់ និងកាប់ឆ្ការលើដីនេះប្រាកដមែនដោយសំអាងថាជាដីរបស់ខ្លួន។ ក្រោយមានរឿងនេះកើតឡើង អាជ្ញាធរឃុំកណ្ដោក បានធ្វើការត្រួតពិនិត្យឯកសារឡើងវិញ និងចេញលិខិតបញ្ជាក់លេខ: ៤១៧ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០ ចំណែកឯកសារដែលជនជាប់ចោទកំពុងយកមកប្រើប្រាស់នោះ ត្រូវបានអាជ្ញាធរ ឃុំកណ្ដោក បញ្ជាក់ថា: ឯកសារនេះ ពុំមានចុះលេខក្នុងសៀវភៅរដ្ឋបាល និងតម្កល់ទុកក្នុងសាលាឃុំឡើយ យោងតាមលិខិតបញ្ជាក់លេខ:៣៩៦ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០។ ទោះបីមានការបញ្ជាក់ពីអាជ្ញាធរឃុំ និងបានឃើញផ្ទាល់នូវឯកសារស្របច្បាប់របស់ជនរងគ្រោះយ៉ាងណាក៏ដោយ ក៏ជនជាប់ចោទឈ្មោះ [redacted] សេងទ្រី មិនបានធ្វើការប្ដឹងផ្ដល់ជាមួយឈ្មោះ [redacted] លាង និងប្រពន្ធឈ្មោះ [redacted] អាត ទេគឺនៅតែអះអាងនៅដំណាក់កាលអយ្យការថា ខ្លួនជាម្ចាស់កម្មសិទ្ធិលើដីនេះដដែល និងបានបន្តប្រើប្រាស់ឯកសារក្លែងបន្លំនេះយកធ្វើជាសំអាងតាមផ្លូវច្បាប់ថែមទៀតផង ។

**នានាពេលសវនាការ ÷**

១. ជនជាប់ចោទឈ្មោះ [redacted] សេងទ្រី បានឆ្លើយថា÷ នៅក្នុងរឿងនេះ ខ្ញុំមិនស្គាល់ឈ្មោះ [redacted] វ៉ាន់នី ឡើយ ហើយខ្ញុំក៏មិនធ្លាប់មានទំនាស់ជាមួយគាត់ពីមុនមកដែរ។ ទើបតែពេលនេះតែប៉ុណ្ណោះដែលគាត់បានធ្វើការប្ដឹងខ្ញុំបាទ ។ ក្នុងរឿងនេះ ខ្ញុំបាទបានទិញដីទំនាស់ខាងលើ ពីឈ្មោះ [redacted] លាង និងប្រពន្ធឈ្មោះ [redacted] អាត កាលពីអំឡុងឆ្នាំ២០០៥ ។ ពេលទិញលក់ដីខាងលើ បានធ្វើកិច្ចសន្យាលក់ទិញត្រឹមត្រូវមានការចូលរួមពីអាជ្ញាធរនៅក្នុងឆ្នាំ២០០៥ តែម្ដង។ ក្រោយពីទិញដីខាងលើបានហើយ ខ្ញុំបាទបានជួលដីនោះឱ្យឈ្មោះ តាទូច ដើម្បី ដាំដំណាំ (បន្លែ ននង ត្រសក់ ពោត សណ្ដែក ...) ។ ដីនោះមានបោះបង្គោលតាមព្រំចំនួន០៤ (បួន) ដើម ។ ចាប់តាំងពីពេលទិញដីនោះ មិនធ្លាប់មានអ្នកណាមកអះអាងថាជាដីរបស់ខ្លួនទេ ទើបតែឆ្នាំ២០១៩ នេះទេដែលមានឈ្មោះ [redacted] វ៉ាន់នី មកប្ដឹងតវ៉ា ។ ឯកសារទិញលក់ដីរបស់ខ្ញុំ គឺខ្ញុំ និងអ្នកលក់នាំគ្នាទៅសាលាឃុំដោយផ្ទាល់ ដើម្បីរៀបចំឯកសារនោះ។ លុះដល់ចុងឆ្នាំ២០១៩ ទើបឈ្មោះ [redacted] វ៉ាន់នី ប្ដឹងខ្ញុំ ។ កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ពេលដែលខ្ញុំទៅ រៀបចំដីនោះ គឺមិនមានវត្តមានរបស់ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត ទេ ។



Scanned with CamScanner

២. ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] លាង បានឆ្លើយថា÷ ខ្លួនមានដី០១ (មួយ) កន្លែងស្ថិតនៅភូមិគោកម៉ា ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលដីនេះមានទំហំបណ្តោយ ១៦២ ម៉ែត្រ ទទឹងទំហំ៥៣ ម៉ែត្រ ហើយមានព្រំប្រទល់ខាងត្បូងទល់នឹងឈ្មោះ [redacted] យ៉ាក ខាងកើតទល់នឹងឈ្មោះ [redacted] យ៉ាត ខាងលិចទល់ឈ្មោះ [redacted] ហស់, ឈ្មោះ [redacted] ផង និងដីរបស់ខ្លួនទៀត និងខាងជើងទល់នឹងឈ្មោះ សេម ។ ចំពោះដីនេះ គឺខ្លួនបានពីការកាប់ឆ្ការ រុករានដីព្រៃ ហើយក្រោយមកដីនេះខ្លួនបានដាំថ្នាំកាតាប និងបានដាំត្រាវ ពោត ឪឡឹក និងម្ទេសបន្ថែមទៀតនៅលើដីនេះ។ ក្រោយមកនៅក្នុងអំឡុងប្រហែលឆ្នាំ១៩៩២ ទៅឆ្នាំ១៩៩៣ ខ្លួនបានលក់ដីនេះទៅឱ្យក្រុមហ៊ុនឈ្មោះ សៀង ចាន់ហេង ក្នុងតម្លៃ ១,៦០០ $ (មួយពាន់ប្រាំមួយរយ) ដុល្លារអាមេរិក ហើយនៅពេលនោះខ្លួនបានទទួលប្រាក់កក់ចំនួន ៥០០,០០០ (ហាសិបម៉ឺន) រៀល ហើយពេលនោះខ្លួនបានផ្តិតមេដៃលើកិច្ចសន្យាលក់ទិញដី និងលិខិតប្រគល់ទទួលប្រាក់កក់លើកទី១ ចំនួនដូចខាងលើ (ហាសិបម៉ឺនរៀល)។ ប៉ុន្តែក្រោយមក ក្រុមហ៊ុនសៀង ចាន់ហេង មិនបានប្រគល់ប្រាក់បង្គ្រប់ថ្លៃដីមកឱ្យខ្លួនទេ រហូតមកដល់ពេលបច្ចុប្បន្ន ។ ហើយខ្លួនក៏បានបន្តការកាន់កាប់រហូតដល់ឆ្នាំ២០១៨ ។ ចាប់តាំងពីឆ្នាំ២០១៨ មកខ្លួនមិនបានទៅធ្វើការបង្កបង្កើនផលទេ មូលហេតុដោយសារគេជីកព្រែកកាត់ មិនអាចឆ្លងគោយន្តទៅភ្ជួរបាន ប៉ុន្តែខ្លួននៅតែបន្តការកាន់កាប់ដដែល។ ចំពោះលិខិតលក់ទិញដីដែលបានធ្វើ នៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៧ នេះជាលិខិតដែលមានលក្ខណៈត្រឹមត្រូវពិតមែន។ ប៉ុន្តែពេលនោះប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] អាត មិនបានចូលរួមផ្តិតមេដៃទេ។ ដោយឡែកឈ្មោះ [redacted] សុធី ខ្លួនមិនដែលស្គាល់ទេ ។ ខ្លួនមិនបានលក់ដីទៅឱ្យឈ្មោះ [redacted] សេងទ្រី ទេ។ ចំពោះក្រយៅដៃលើកិច្ចសន្យាលក់ទិញផ្ទះផ្តាច់ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ មានមេដៃ និងឈ្មោះរបស់ខ្លួននៅលើនោះ គឺខ្លួនមិនបានផ្តិតទេ។ សព្វថ្ងៃនេះខ្លួននៅតែកាន់កាប់ដីនេះដដែលមិនបានប្រគល់ឱ្យអ្នកណាឡើយ ដោយហេតុថា អ្នកទិញបានប្រគល់លុយកក់ឱ្យខ្លួនចំនួន ៥០០,០០០ (ហាសិបម៉ឺន) រៀល ក្នុងតម្លៃដីសរុបចំនួន ១,៦០០$ (មួយពាន់ប្រាំមួយរយ) ដុល្លារអាមេរិក។ បច្ចុប្បន្នខ្លួនមានបំណងឱ្យដើមបណ្តឹងចូលមកដើម្បីផ្សះផ្សារ ដោយខ្លួនសូមសំណូមពរឱ្យដើមបណ្តឹងកាត់ដីនេះទំហំក្បាល២០ ម៉ែត្រ បណ្តោយ៣០ ម៉ែត្រ និងជំរើសទី២ គឺសូមឱ្យដើមបណ្តឹងចេញជាប្រាក់ ១០,០០០$ (មួយម៉ឺន) ដុល្លារអាមេរិក ។ ខ្លួនសូមសំណូមពរដល់តុលាការមេត្តាកុំឃុំខ្លួនរូបខ្លួនអី ព្រោះខ្លួនមានជំងឺប្រចាំកាយ គឺហើមពោះវៀន។

៣. ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] អាត បានឆ្លើយថា÷ ខ្លួនពិតជាមានដីមួយកន្លែងស្ថិតនៅភូមិគោកម៉ា ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលដីនេះមានបណ្តោយទំហំ ១៦២ម៉ែត្រ និងទទឹងទំហំ ៥៣ម៉ែត្រ មានព្រំប្រទល់ខាងត្បូងទល់នឹងឈ្មោះ [redacted] យ៉ាក ខាងកើតទល់នឹងឈ្មោះ [redacted] យ៉ាក ខាងលិចទល់នឹងឈ្មោះ [redacted] លាស់ និងខាងជើងទល់នឹងឈ្មោះ សេម ។ ចំពោះដីនេះខ្លួនបានមកពីការកាប់ឆ្ការរុករានដីព្រៃ ហើយបានដាំដំណាំដូចជា ថ្នាំកាតាប ត្រាវ ពោត ឪឡឹក ម្ទេសបន្ថែមទៀតនៅលើដីនេះទៀតផង។ ក្រោយមកនៅក្នុងអំឡុងឆ្នាំ១៩៩២ ទៅឆ្នាំ១៩៩៣ ខ្លួន និងប្តីបានលក់ដី

នេះទៅឱ្យក្រុមហ៊ុន សៀង ចាន់ហេង ក្នុងតម្លៃ១,៦០០(មួយពាន់ប្រាំមួយរយ) ដុល្លារអាមេរិក ប៉ុន្តែពេលទៅយកលុយកក់ដីនោះចំនួន ៥០០,០០០(ហាសិបម៉ឺន) រៀល គឺខ្លួនមិនបានទៅយកលុយទេ គឺប្ដីខ្លួនជាអ្នកទទួលផ្ដិតមេដៃទទួលប្រាក់កក់ថ្លៃដីនោះចំនួន ៥០០,០០០ (ហាសិបម៉ឺន) រៀល ។ ក្រោយពេលកក់ប្រាក់ថ្លៃដីលើកទី១ហើយ ក្រុមហ៊ុន សៀង ចាន់ហេង មិនបានប្រគល់ប្រាក់ថ្លៃដីបង្គ្រប់មកឱ្យខ្លួន និងប្ដីឡើយ ហើយដីនេះ ខ្លួន និងប្ដីបានបន្តការកាន់កាប់អាស្រ័យផល រហូតមកដល់សព្វថ្ងៃនេះ។ ចំពោះលិខិតលក់ទិញដីដែលបានធ្វើនៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៧ នេះ ខ្លួនមិនបានចូលរួមផ្ដិតមេដៃទេគឺប្ដីរបស់ខ្លួនជាអ្នកផ្ដិតមេដៃ ព្រោះពេលនោះនាងខ្ញុំជាប់ឆ្លងទន្លេកូនខ្ចី។ ខ្លួនមិនបានលក់ដីឱ្យឈ្មោះ [redacted] សេងទ្រី នេះទេ ។ សព្វថ្ងៃខ្លួននៅតែបន្តកាន់កាប់នៅលើដីនេះដដែល។ មូលហេតុដោយសារ ខាងក្រុមហ៊ុន សៀង ចាន់ហេង មិនទាន់បានទូទាត់ថ្លៃដីបង្គ្រប់មកឱ្យខ្លួន និងប្ដីឡើង។ បច្ចុប្បន្ននេះ ខ្លួនមានបំណងចង់ឱ្យដើមបណ្ដឹងចូលមកដើម្បីធ្វើការផ្សះផ្សារ ដោយខ្លួនសូមសំណូមពរឱ្យដើមបណ្ដឹងកាត់ដីនេះ ទំហំក្បាល២០ម៉ែត្រ និងបណ្ដោយទំហំ ៣០ម៉ែត្រ និងជំរើសទី២ សូមឱ្យដើមបណ្ដឹងចេញជាប្រាក់ចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក មកឱ្យខ្លួន និងប្ដី ។ ខ្លួនសូមសំណូមពរដល់តុលាការមេត្តាកុំឃុំរឹបខ្លួនអី ព្រោះខ្លួនមានកូនក្នុងបន្ទុកចំនួន ០៤ (បួន) នាក់ ត្រូវចិញ្ចឹម និងមានជំងឺតេងមិនលក់ថែមទៀតផង។

៤. ក្រឡាបញ្ជីអានកំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] វ៉ាន់នី ថា÷ ខ្លួនសុំរក្សាទុកពាក្យបណ្ដឹង ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ នៅដដែល។ ខ្លួនមានដីមួយកន្លែងទំហំ៨,៥៨៦ ម៉ែត្រការ៉េ មានទីតាំងស្ថិតក្នុងភូមិអំពៅព្រៃ (អតីតភូមិគោកម៉ា) ឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល (បច្ចុប្បន្នស្ថិតក្នុងភូមិទួលក្រសាំង សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្ដាល) មានព្រំប្រទល់ខាងជើងទល់ទំនប់, ខាងកើតទល់នឹងឈ្មោះ តាម៉ាប់ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ាប់ និងខាងលិចទល់នឹងទំនប់ ដោយមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ៣៥៩/១៥ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ចុះហត្ថលេខាដោយមេឃុំកណ្ដោកលោក [redacted] ចាន់ ពីឈ្មោះ [redacted] សុធី (អ្នកផ្ទេរសិទ្ធិ) មកខ្លួន (អ្នកទទួលសិទ្ធិ)។ មុនមានការផ្ទេរសិទ្ធិដីខាងលើនេះ គឺជារបស់ឈ្មោះ [redacted] លាង (ជនសង្ស័យ) បានលក់មកឱ្យលោកស្រី [redacted] ចាន់ហេង តាមរយៈតំណាងគឺលោក [redacted] សុធី ដែលមានលិខិតលេខ០៧/៩៧ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៧ ចុះហត្ថលេខាដោយមេភូមិអំពៅព្រៃ លោក [redacted] សារឿន និងហត្ថលេខារបស់មេឃុំកណ្ដោក លោក [redacted] ចាន់ ត្រឹមត្រូវ ។ ក្រោយមក នៅឆ្នាំ២០១៥ ឈ្មោះ [redacted] សុធី បានផ្ទេរសិទ្ធិដីនេះជូនមកខ្លួន។ ក្រោយពីមានការផ្ទេរសិទ្ធិដីធ្លីពីឈ្មោះ [redacted] សុធី នៅឆ្នាំ២០១៥ មក ខ្លួនបានកាន់កាប់ ប្រើប្រាស់ ថាត់ថែង និងអាស្រ័យផលរួចមក ខ្លួនបានចូលទៅធ្វើរបងខ្សែរលួស កាយប្រឡាយលើកជាទំនប់ព័ទ្ធជុំវិញដីរួច ហើយដាំដំណាំហូបផ្លែជាបន្តបន្ទាប់មាន ល្មុង (ងាប់) និងដើមចេក មកទល់បច្ចុប្បន្ន។ គិតចាប់ពីពេលធ្វើការផ្ទេរសិទ្ធិនៅឆ្នាំ២០១៥ រហូតមក គឺមិនមាននរណាចេញមុខមកតវ៉ាប្រឆាំងលើដីរបស់ខ្លួននេះទេ។ លុះមកដល់អំឡុងឆ្នាំ២០១៩ ពេលដីនៅតំបន់នោះឡើងថ្លៃ ស្រាប់តែ

លេចឈ្មោះ [redacted] សេងទ្រី មកតវ៉ាទាមទារថាខ្លួនជាម្ចាស់កម្មសិទ្ធិដីរបស់ខ្លួននេះ ដោយយកកិច្ចសន្យាលក់ផ្តាច់ដីផ្ទះ លេខ០៤/០៥យកជ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៥ ចុះហត្ថលេខាដោយមេភូមិរងលោក [redacted] តិច (ស្លាប់) និងចុះហត្ថលេខាដោយមេឃុំកណ្តោក លោក [redacted] មឿន (ស្លាប់) មកបង្ហាញនៅចំពោះមុខខ្លួន និងប្រគល់មកឱ្យខ្លួនពិនិត្យ (ថតចម្លង)។ បន្ទាប់ពីបានពិនិត្យមើលលិខិតនេះរួចឃើញថា មានភាពមិនប្រក្រតីជាច្រើនរួមមាន÷ ចុះហត្ថលេខាដោយមេភូមិរង តម្លៃដីត្រឹមតែ១,៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក ថោកពេក និងចំណុចមួយទៀត ត្រង់ថាឈ្មោះ [redacted] លាង បានលក់ដីនេះឱ្យឈ្មោះ [redacted] សេងទ្រី ក្នុងឆ្នាំ២០០៥ ទំហំ៨,៥០០ ម៉ែត្រការ៉េ នៅទីតាំងដដែរ ដែលខ្លួន ([redacted] លាង) ធ្លាប់លក់ទៅឱ្យឈ្មោះ [redacted] សុធី តាំងពីឆ្នាំ១៩៩៧ ម្តងរួចទៅហើយ ខ្លួនក៏បានយកលិខិតនេះទៅសាលាឃុំកណ្តោក ដើម្បីឱ្យគាត់ជួយពិនិត្យថា កិច្ចសន្យាលក់ផ្តាច់ដីផ្ទះលេខ០៤ /០៥យកជ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៥ ដែលមានចុះហត្ថលេខារដ្ឋបាលឃុំនេះត្រឹមត្រូវដែរឬទេ ? ក្រោយពីសាលាឃុំកណ្តោកពិនិត្យស្រាវជ្រាវចប់ លោកមេឃុំកណ្តោកឈ្មោះ [redacted] ចាន់ បានចេញលិខិតលេខ ៣៩៦៧.ប ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ ដោយបញ្ជាក់ថា លិខិតលេខ ០៤/០៥យកជ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៥ របស់ឈ្មោះ [redacted] លាង និងមានប្រពន្ធឈ្មោះ [redacted] អាត គឺពុំមានចុះលេខក្នុងសៀវភៅរដ្ឋបាល ឆ្នាំ២០០៥ ទេ រួមទាំងពុំមានតម្កល់នៅរដ្ឋបាលឃុំផងដែរ ដូចនេះសាលាឃុំកណ្តោកបានធ្វើការបដិសេធលិខិតនេះ។ បន្ថែមពីលើនេះ ដើម្បីបញ្ជាក់ពីភាពស្អាតស្អំ ត្រឹមត្រូវរបស់ខ្លួន ក្នុងការកាន់កាប់ដីខាងលើនេះ ខ្លួនក៏បានស្នើលោកមេឃុំកណ្តោកមេត្តាជួយ ចេញលិខិតបញ្ជាក់ជូនខ្លួន ទើបលោកមេឃុំកណ្តោក ចេញលិខិតបញ្ជាក់ចំនួនពីរច្បាប់ មានលិខិតបញ្ជាក់អំពីការគ្រប់គ្រងដីរដ្ឋបាលពីមុន និងបច្ចុប្បន្ន លេខ ៤១៨ ល.បជ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០ (បញ្ជាក់ពីឈ្មោះភូមិគោកម៉ា និងភូមិអំពៅព្រៃ) និងលិខិតបញ្ជាក់លេខ៤១៧ ល.ប.ជ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០ ដែលបញ្ជាក់អំពីភាពត្រឹមត្រូវនៃលិខិតលេខ០៧/ ៩៧ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៧ រវាងឈ្មោះ [redacted] លាង (អ្នកលក់) និងឈ្មោះ [redacted] ចាន់ហេង តំណាងដោយឈ្មោះ [redacted] សុធី (អ្នកទិញ) និងលិខិតលេខ ៣៥៥/១៥ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ រវាង ឈ្មោះ [redacted] សុធី (អ្នកផ្ទេរសិទ្ធិ) និងខ្ញុំ (អ្នកទទួលសិទ្ធិ)។ លិខិតទាំងពីរនេះគឺបានចុះលេខ ក្នុងសៀវភៅរដ្ឋបាល និងរក្សាទុកជាឯកសារនៅសាលាឃុំប្រាកដមែន។ សំណូមពរ សុំឱ្យតុលាការចោទប្រកាន់ និងផ្តន្ទាទោសជនល្មើសតាមច្បាប់ និងទាមទារសំណងជំងឺចិត្តចំនួន៥០០,០០០ (ហាសិបម៉ឺន) ដុល្លារអាមេរិក ព្រមទាំងទទួលស្គាល់ដីខាងលើជាកម្មសិទ្ធិរបស់ខ្លួន។

៥.លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា÷ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមក និងក្រោយពីបានស្តាប់ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត ឃើញថា អ្នកទាំងពីរមិនមានទំនាក់ទំនងទិញលក់ដីជាមួយឈ្មោះ [redacted] សេងទ្រី ទាល់តែសោះ។ នៅក្នុងរឿងនេះ ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត បានឆ្លើយហើយថា ពួកគាត់បានលក់ដីខាងលើឱ្យក្រុមហ៊ុន សៀង ចាន់ហេង។

ក្រោយមក កូនក្តីខ្ញុំបានទទួលការផ្ទេរសិទ្ធិលើដីនេះ តាមរយៈក្រុមហ៊ុន សៀង ចាន់ហេង ដែលមានឈ្មោះ [redacted] សុធី ជាអ្នកតំណាង តាមរយៈលិខិតផ្ទេរសិទ្ធិ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ហើយឯកសារទាំងអស់នេះ ពិតជាអាចបញ្ជាក់បានថា កូនក្តីរបស់នាងខ្ញុំពិតជាបានទិញដីខាងលើត្រឹមត្រូវស្រប តាមច្បាប់ពិតមែន ។ ហេតុដូច្នេះ នាងខ្ញុំស្នើសុំឱ្យតុលាការសម្រេចតម្កល់ការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] លាង, ឈ្មោះ [redacted] អាត និងឈ្មោះ [redacted] សេងទ្រី តាមដីកាសន្និដ្ឋានស្ថាពរលេខ ១២២៣ ដកសព ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ ទុកជាបានការដដែល ។

**៦. តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា÷** ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមក ឃើញថា នៅតែមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទដដែល ។ ហេតុនេះ តំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់ដូចនៅក្នុងដីកាសន្និដ្ឋានស្ថាពរលេខ១២២៣ ដកសព ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២១ ទុកជាបានការដដែល ។

**៧. លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត បានធ្វើសេចក្តីសន្និដ្ឋានថា÷** ឆ្លងតាមលទ្ធផលនៃការសួរដេញដោល និងតាមការពិនិត្យឯកសារភស្តុតាងនានានៅក្នុងសំណុំរឿង ឃើញថា នៅក្នុងរឿងនេះ តុលាការចោទប្រកាន់មកលើកូនក្តីខ្ញុំបាទចំនួន០៣ (បី) បទល្មើសគឺ÷ បទល្មើសទី១ "ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, បទល្មើសទី២ "លួចលក់អចលនវត្ថុមិនមែនជារបស់ខ្លួន និងបទល្មើសទី៣ "ប្រើប្រាស់ឯកសារសាធារណៈក្លែង" ប្រព្រឹត្តនៅភូមិអំពៅព្រៃ ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០២០ តាមមាត្រា ៣៥៣, មាត្រា៣៥៥ នៃច្បាប់ភូមិបាល និងមាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ ។ បើពិនិត្យទៅលើអង្គហេតុក្នុងពាក្យបណ្តឹង ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០ របស់ដើមបណ្តឹងប្តឹងចូលមកអយ្យការអមសាលាដំបូងខេត្តកណ្តាល និងពាក្យបណ្តឹង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ របស់ដើមបណ្តឹងប្តឹងចូលមកស្នងការនគរបាលខេត្តកណ្តាល ប្តឹងពីឈ្មោះ [redacted] សេងទ្រី និងបក្សពួក ពីបទ÷ ធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ និងពាក្យបណ្តឹង ចុះថ្ងៃទី០៤ ខែ ឧសភា ឆ្នាំ២០២០ របស់ដើមបណ្តឹងប្តឹងចូលមកអយ្យការអមសាលាដំបូងខេត្តកណ្តាល ប្តឹងពីឈ្មោះ [redacted] លាង, ឈ្មោះ [redacted] អាត, ឈ្មោះ [redacted] សេងទ្រី និងបក្សពួក ពីបទ÷ លួចលក់អចលនវត្ថុអ្នកដទៃ, សមគំនិតនិងទទួលផលចោរកម្ម ដោយមិនបានបញ្ជាក់អំពីកាលបរិច្ឆេទ និងទីកន្លែងប្រព្រឹត្តទេ។ ក្រោយមកតំណាងអយ្យការនៃសាលាដំបូងខេត្តកណ្តាល បានបើកការស៊ើបសួរលើអង្គហេតុខាងលើ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១០១២ កសស ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យលើឈ្មោះ [redacted] លាង, ឈ្មោះ [redacted] អាត , ឈ្មោះ [redacted] សេងទ្រី រួមទាំងបក្សពួក ពីបទ÷ ហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន និងប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅភូមិអំពៅព្រៃ ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០២០។ ក្រោយមកតំណាងអយ្យការបានចេញដីកាសន្និដ្ឋានស្ថាពរលេខ ១២២៣



Scanned with CamScanner

ដកសព ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ ដោយសម្រេចបញ្ជូនជនត្រូវចោទ ឈ្មោះ [redacted] លាង, ឈ្មោះ [redacted] អាត និងឈ្មោះ [redacted] សេងទ្រី ប្រព្រឹត្តនៅភូមិអំពៅព្រៃ ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០២០ តាមមាត្រា២៥៣ និងមាត្រា២៥៤ នៃច្បាប់ភូមិបាល និងមាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ ទៅជំនុំជម្រះ ។

បើផ្អែកទៅលើអង្គហេតុចោទប្រកាន់លើឈ្មោះ [redacted] លាង, ឈ្មោះ [redacted] អាត និងឈ្មោះ [redacted] សេងទ្រី ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាអង្គហេតុដែលដើមបណ្តឹងឈ្មោះ [redacted] វ៉ាន់ឌី ប្តឹងពីឈ្មោះ [redacted] សេងទ្រី និងបក្សពួក ពីបទ÷ ធ្វើឱ្យខូចខាតដោយចេតនា ដោយបានបញ្ជាក់នូវអង្គហេតុថា កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ឈ្មោះ [redacted] សេងទ្រី និងបក្សពួកបានធ្វើសកម្មភាពចូលមករំលោភបំពាន និងបានកាប់បំផ្លាញដំណាំលើដីរបស់ខ្លួន។ អង្គហេតុនេះមិនពាក់ព័ន្ធនឹងឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត នោះទេ ហើយឈ្មោះ [redacted] សេងទ្រី ក៏បានបញ្ជាក់នៅក្នុងអង្គសវនាការថា នៅថ្ងៃកើតហេតុ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ នោះមិនមានវត្តមានរបស់ឈ្មោះ [redacted] ហេង និងឈ្មោះ [redacted] អាត ចូលរួមនោះទេ ។

ចំពោះបទចោទទាំង០៣ខាងលើ តំណាងអយ្យការធ្វើការចោទប្រកាន់មកលើកូនក្តីខ្ញុំបាទនេះ មិនមានភស្តុតាង និងធាតុផ្សំបទល្មើសគ្រប់គ្រាន់ក្នុងការចោទប្រកាន់មកលើកូនក្តីខ្ញុំបាទនោះទេ ពីព្រោះថា ទាក់ទងនឹងបទចោទ ហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត កូនក្តីខ្ញុំបាទមិនបានប្រព្រឹត្តនោះទេ ដូចដែលឈ្មោះ [redacted] សេងទ្រី បានបញ្ជាក់ជូនអង្គសវនាការថា នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ មិនមានវត្តមានឈ្មោះ [redacted] លាង , ឈ្មោះ [redacted] អាត នៅកន្លែងកើតហេតុនោះទេ ។ រីឯបទចោទលួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ក៏មិនមានអង្គហេតុ ឬភស្តុតាងណាមួយបញ្ជាក់ថា ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត បានលួចលក់អចលនវត្ថុអ្នកដទៃនោះដែរ ទោះបីលទ្ធផលកោសល្យវិច័យដែលចេញមកបញ្ជាក់ថា ស្នាមមេដៃដែលផ្តិតនៅលើកិច្ចសន្យាលក់ផ្តាច់ដី-ផ្ទះ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ជាស្នាមមេដៃរបស់ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត ក៏ដោយ ក៏ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត មិនមានកំហុសនោះដែរ ព្រោះដីដែលជាកម្មវត្ថុនៃការលក់ទិញនេះ នៅតែជាកម្មសិទ្ធិស្របច្បាប់របស់ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត ដដែល ដោយហេតុថា កាលពីអំឡុងឆ្នាំ ១៩៩៧ ក្រុមហ៊ុនលោកស្រី សៀង ចាន់ហេង ដែលតំណាងដោយលោក [redacted] សុធី បានចុះកិច្ចសន្យាលក់ទិញដីពីឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត ពិតប្រាកដមែន ប៉ុន្តែខាងក្រុមហ៊ុនទើបតែបានកក់ប្រាក់លើកទី១ ឱ្យទៅឈ្មោះ [redacted] លាង, ឈ្មោះ [redacted] អាត បានចំនួន ៥០០,០០០ (ហាសិបម៉ឺន) រៀល ប៉ុណ្ណោះ ហើយក្រុមហ៊ុនមិនបានបំពេញកាតព្វកិច្ចប្រគល់ប្រាក់ថ្លៃទិញដីបង្គ្រប់ឱ្យទៅឈ្មោះ [redacted] លាង, ឈ្មោះ [redacted] អាត ទេ ចាប់តាំងពីឆ្នាំ១៩៩៧ មក។ ការដែលឈ្មោះ [redacted] សុធី (តំណាងក្រុមហ៊ុន សៀង ចាន់ហេង) យកដីដែលជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] លាង, ឈ្មោះ [redacted] អាត ទៅលក់បន្តឱ្យឈ្មោះ [redacted] វ៉ាន់ឌី នេះគឺជាអំពើខុសច្បាប់ ដោយហេតុថា ឈ្មោះ [redacted] សុធី គ្រាន់តែជាតំណាងឱ្យក្រុមហ៊ុនប៉ុណ្ណោះ ហើយក្រុមហ៊ុនមិនទាន់ក្លាយជាម្ចាស់កម្មសិទ្ធិលើដីដែលជាកម្មវត្ថុនៃការលក់ទិញ នេះនៅឡើយទេ ដោយខាងក្រុមហ៊ុនមិន

បានបំពេញកាតព្វកិច្ចឱ្យបានចប់សព្វគ្រប់ ហើយបានបោះបង់ចោលការទិញលក់ និងប្រាក់កក់នោះ។ ចំពោះបទចោទប្រើប្រាស់ឯកសារសាធារណៈក្លែង ក៏មិនមានភស្តុតាងណាមួយបញ្ជាក់ថា ឈ្មោះ [redacted] លាង ឈ្មោះ [redacted] អាត បានប្រព្រឹត្តដែរ ដោយហេតុថា ឯកសារកិច្ចសន្យាលក់ផ្តាច់ដី និងផ្ទះ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ មិនមាននៅលើដៃរបស់ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត នោះទេ ។ ឯកសារទាំងអស់នេះគឺ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វ៉ាន់នី ជាអ្នកភ្ជាប់ជាមួយនូវពាក្យបណ្តឹងពេលដែលដាក់ជូនតុលាការ ។

៨.លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សេងទ្រី បានធ្វើសេចក្តីសន្និដ្ឋានថា÷ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ឈ្មោះ [redacted] លាង និងប្រពន្ធឈ្មោះ [redacted] អាត បានធ្វើការលក់ផ្តាច់ដីមួយកន្លែង មានបណ្តោយប្រវែង១៧០ ម៉ែត្រ និងទទឹង ៥០ ម៉ែត្រ មានទីតាំងស្ថិតនៅ ភូមិពោកម៉ា ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល (សព្វថ្ងៃប្តូរមកជាភូមិទួលក្រសាំង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល) ក្នុងតម្លៃ USD ១,៥០០ (មួយពាន់ប្រាំរយដុល្លារអាមេរិកត់) ឱ្យកូនក្តីយើងខ្ញុំឈ្មោះ [redacted] សេងទ្រី និងប្រពន្ធឈ្មោះ [redacted] រីម និងបានធ្វើការប្រគល់ប្រាក់គ្រប់ចំនួន ដូចបានបញ្ជាក់ក្នុងកិច្ចសន្យាលក់ផ្តាច់ដី-ផ្ទះ លេខ០៤/០៥ ឃ.ក.ឋ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៥ របស់ឈ្មោះ [redacted] លាង, ឈ្មោះ [redacted] អាត (អ្នកលក់) និងឈ្មោះ [redacted] សេងទ្រី (អ្នកទិញ) បានឃើញ និងបញ្ជាក់ដោយមេឃុំកណ្តោក ឈ្មោះ [redacted] មឿន ដូចក្នុងឯកសារភ្ជាប់។ នៅកាលបរិច្ឆេទនៃការទិញ- លក់ទីតាំងដីនេះ កូនក្តីយើងខ្ញុំបានធ្វើការដាក់ពាក្យស្នើសុំកាន់កាប់ដីធ្លី ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ ២០០៥ ដោយមានការទទួលស្គាល់ពីមេឃុំកណ្តោក។ បន្ទាប់ពីទិញដីនេះរួចភាគីអ្នកលក់បាននាំកូនក្តីខ្ញុំបាទចង្អុលបង្ហាញព្រំ និងធ្វើការវាស់វែងដើម្បីបញ្ជាក់ពីទីតាំង និងទំហំដី ដោយកូនក្តីយើងខ្ញុំបានធ្វើការបោះបង្គោលស៊ីម៉ង់ចំនួន០៤ (បួន) ដើម ដើម្បីសម្គាល់ព្រំដី។ មួយរយៈក្រោយមកកូនក្តីយើងខ្ញុំ បានធ្វើការជួលទីតាំងដីនេះឱ្យទៅលោកតាទូច និងយាយ វ៉ាន់ ក្នុងតម្លៃ ៤០០,០០០៛ (សែសិបម៉ឺនរៀល) ក្នុង ០១ (មួយ) ឆ្នាំ។ ក្រោយពេលជួល ពួកគាត់បានកាប់ឆ្ការព្រៃអូយ៉ាស់ និងបានធ្វើការភ្ជួររាស់ដីដាំបន្លែបង្ការជាច្រើនមុខ ដើម្បីធ្វើការលក់ដូរ និងផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ រហូតដល់ឆ្នាំ២០១២ ទើបតាយាយឈប់ជួលដីនេះ។ នៅឆ្នាំ២០១២ នេះដដែល កូនក្តីរបស់យើងខ្ញុំបានស្នើសុំឈ្មោះ [redacted] ហ៊ុន ភេទប្រុស អាយុប្រហែល៥០ឆ្នាំ ដែលមានផ្ទះនៅក្បែរដីឱ្យជួយមើលការខុសត្រូវ និងជួយថែរក្សាដីនេះ ហើយក្រុមគ្រួសារកូនក្តីយើងខ្ញុំ តែងតែឡើង ចុះមើលថែដីនេះជាប្រចាំមិនដែលអាក់ខានឡើយ។ម្យ៉ាងទៀត ដីនៅទីនោះ នាខែវស្សាទឹកលិច ចំណែកឯខែប្រាំង កូនក្តីយើងខ្ញុំបានដាំដំណាំមានដូចជា ននោង ពោត និងសណ្តែក។ កូនក្តីយើងខ្ញុំបានកាន់កាប់ដោយមាន ការដឹងឮជាសាធារណៈ ដោយគ្មានការលាក់លៀម គ្មានអាថិកំបាំង ការកាន់កាប់ដោយគ្មានហិង្សា គ្មានការតវ៉ាពីបុគ្គលណាឡើយ ចំពោះការកាន់កាប់ដីខាងលើដែលបានមកពីការលក់ទិញរវាងកូនក្តីយើងខ្ញុំ និងឈ្មោះ [redacted] លាង ប្រពន្ធឈ្មោះ [redacted] អាត។



Scanned with CamScanner

ក្នុងអំឡុងខែមីនា ឆ្នាំ២០១៩ នៅពេលដែលកូនក្តីយើងខ្ញុំចូលទៅកាប់ឆ្កាព្រៃអូយ៉ាស់ ស្រាប់តែឈ្មោះ [redacted] ភ័ន់ឌី បានហាមឃាត់មិនឱ្យកូនក្តីខ្ញុំបាទធ្វើការកាប់ឆ្កាព្រៃ មិនឱ្យចូលកាន់កាប់ និងមិនឱ្យចូលទីតាំងដីទៅវិញ លើសពីនេះទៀត ដើមបណ្តឹងឈ្មោះ [redacted] ភ័ន់ឌី បានដាក់ពាក្យបណ្តឹងប្តឹងកូនក្តីយើងខ្ញុំទៅសមត្ថកិច្ច និងតុលាការពាក់ព័ន្ធនឹងដីខាងលើ ដូចមានក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៧៤៩ អ.ក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាល ពីបទ "ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត", បទ "លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន និងប្រើប្រាស់ឯកសារសារធារណៈក្លែង"។

ផ្អែកតាមមាត្រា២៥៣ នៃច្បាប់ភូមិបាលចែងថា "ជនណាដែលប្រើប្រាស់អំពើហិង្សាទៅលើអ្នកកាន់ កាប់អចលនវត្ថុដោយសុចរិត ត្រូវពិន័យជាប្រាក់ ១លាន ៥សែនរៀល ទៅ២៥ លានរៀល ឬ/និងដាក់ពន្ធនាគារពី៦ ខែទៅ២ ឆ្នាំ។ ជាទូទៅ មុននឹងឈានដល់ការកំណត់បទល្មើសខាងលើ គប្បីពិចារណាថាតើនរណាជាម្ចាស់កម្មសិទ្ធិ?

**ក. មូលដ្ឋានគតិយុត្ត÷** លិខិតទិញ-លក់ ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ១៩៩៧ រវាងអ្នកលក់ ([redacted] លាង និងឈ្មោះ [redacted] អាត) និងអ្នកទិញ ([redacted] ចាន់ហេង ដោយមានការតំណាងដោយគ្មានសិទ្ធិពីឈ្មោះ [redacted] សុធី) គឺមានការកក់ប្រាក់ចំនួន ៥០០,០០០ (ហាសិបម៉ឺន) រៀល ស្របតាមប្បញ្ញត្តិនៃមាត្រា៥១៨ នៃក្រមរដ្ឋប្បវេណី។ បន្ទាប់ពីការកក់ប្រាក់រួច អ្នកទិញពុំបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាជនសុចរិតឡើយ ផ្អែកតាមកំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ [redacted] លាង ដែលជាភាគីអ្នកលក់ ក្នុងដំណាក់កាលអយ្យការ។ ករណីនេះ ចំពោះប្រាក់កក់ខាងលើ បើពិនិត្យមើលនិយមន័យនៃវត្ថុដែលបានប្បញ្ញត្តិនៅក្នុងមាត្រា១១៩ នៃក្រមរដ្ឋប្បវេណី មិនបានកំណត់ថាប្រាក់ជាវត្ថុឡើយ ហើយរិតតែមិនអាចយកប្រាក់ជាប្រាតិភោគបានឡើយ មានន័យថា ប្រាក់កក់នេះគឺជាប្រភេទសិទ្ធិលើបំណុល ដែលបានផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលមានអំឡុងពេល០៥ឆ្នាំ ផ្អែកតាមមាត្រា៤៨២ នៃក្រមរដ្ឋប្បវេណី ។ បើពិនិត្យមើលលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃ២៣ ខែមីនា ឆ្នាំ២០១៥ វិញ ឃើញថាឈ្មោះ [redacted] សុធី ដែលបានអះអាងថាជាអ្នកតំណាងលើការទិញដីឱ្យឈ្មោះ សៀង ចាន់ហេង នោះគឺជាការតំណាងដោយគ្មានសិទ្ធិផ្អែកតាមមាត្រា៣៦៥ នៃក្រមរដ្ឋប្បវេណី។ ជាលទ្ធផលនាំឱ្យឈ្មោះ [redacted] ភ័ន់ឌី ដែលបានធ្វើលទ្ធកម្មពីឈ្មោះ [redacted] សុធី ពុំមានសុពលភាពឡើយ ព្រោះឈ្មោះ [redacted] សុធី ធ្វើការលក់កម្មសិទ្ធិរបស់អ្នកដទៃដែលផ្ទុយពីប្បញ្ញត្តិស្តីពីកិច្ចសន្យាលក់ទិញដែលមានចែងដោយក្រមរដ្ឋប្បវេណីផង និងផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ត្រង់មាត្រា៤៤ កថាខណ្ឌទី២ ផង ។

**ខ. មូលដ្ឋាននៃសេចក្តីសម្រេចរបស់តុលាការជាន់ខ្ពស់÷** សាលដីការដ្ឋប្បវេណីលេខ០៥ ក្រV.ទល ចុះថ្ងៃទី២៦-០៤-២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់សេចក្តីសម្រេចបញ្ចប់ ចំណុចទី៤ សម្រេចប្រគល់ដីដែលមានបណ្តោយប្រវែង១៧០ ម៉ែត្រ និងទទឹងប្រវែង៥០ម៉ែត្រ ស្ថិតនៅភូមិគោកម៉ា ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលសព្វថ្ងៃប្តូរមកជាភូមិទួលក្រសាំង សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ

ខេត្តកណ្តាល ដែលមានពាក្យស្នើសុំកាន់កាប់ដីធ្លីលេខ០៥/០៥ ឃ.ក.ផ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៥ បានឃើញ និងបញ្ជាក់ដោយមេឃុំកណ្តោក មកឱ្យដើមចោទឈ្មោះ [redacted] សេងទី គ្រប់គ្រងជាកម្មសិទ្ធិ ។ ដោយឡែក សេចក្តីសម្រេចរបស់តុលាការជាន់ខ្ពស់ខាងលើនេះ ជាដំណោះស្រាយនូវបញ្ហាបន្ទាន់បង្ហែ ដែលជាអញ្ញត្រកម្មនៃនីតិវិធីព្រហ្មទណ្ឌ។ ផ្អែកតាមមាត្រា៣៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ថា បញ្ហាបន្ទាន់បង្ហែ គឺជាបញ្ហាដែលអាចនឹងលុបលាងចរិតជាបទល្មើសពីអំពើដែលចោទប្រកាន់ ហើយបញ្ហាបន្ទាន់បង្ហែទាក់ទងនឹងបញ្ហាស្តីពីកម្មសិទ្ធិ សិទ្ធិប្រត្យក្សលើអចលនវត្ថុ និងរឿងឋានៈបុគ្គល។ ជាក់ស្តែង សេចក្តីសម្រេចអំពីបញ្ហាកម្មសិទ្ធិត្រូវបានសម្រេចដោយតុលាការជាន់ខ្ពស់រួចហើយ ដូច្នេះបទល្មើសដែលរងការចោទប្រកាន់គឺពុំអាចទៅរួចឡើយ ។

**គ. ការបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិកម្មសិទ្ធិ÷** កិច្ចសន្យាលក់ផ្តាច់ដី-ផ្ទះលេខ០៤/០៥ ឃ.ក.ផ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៥ របស់ឈ្មោះ [redacted] លាង, ឈ្មោះ [redacted] អាត (អ្នកលក់) និងឈ្មោះ [redacted] សេងទ្រី (អ្នកទិញ) បានឃើញ និងបញ្ជាក់ដោយមេឃុំកណ្តោកឈ្មោះ [redacted] មឿន បង្កើតឡើងដោយស្របតាមឆន្ទៈរបស់ភាគី និងបានអនុវត្តកាតព្វកិច្ចចប់សព្វគ្រប់អស់ហើយ ដោយប្រគល់ប្រាក់នៃការលក់ទិញគ្រប់ចំនួន ព្រមទាំងមានលិខិតបញ្ជាក់ផងដែរពីអាជ្ញាធរមូលដ្ឋាន ដូចជាពាក្យស្នើសុំកាន់កាប់ដីធ្លី, លិខិតបញ្ជាក់ប្រវត្តិដី និងឯកសារបញ្ជាក់ដ៏ទៃទៀត ក៏ដូចជាបានដាក់ពាក្យស្នើសុំធ្វើប័ណ្ណកម្មសិទ្ធិ ស្របតាមនីតិវិធីរដ្ឋបាលសុរិយោដី និងតាមនីតិវិធីច្បាប់។ ប្រសិនបើឯកសាររបស់កូនក្តីយើងខ្ញុំមានភាពមិនប្រក្រតីណាមួយនោះ ខាងអាជ្ញាធរមូលដ្ឋាន និងមន្ត្រីភូមិបាលមិនបន្តនីតិវិធីលើពាក្យស្នើសុំចុះបញ្ជីឡើយ។ ដោយឡែក ចំពោះបទល្មើស "លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន" ផ្អែកតាមមាត្រា ២៥៥ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ពុំមានភាពសមហេតុផលឡើយ ព្រោះថាការធ្វើលទ្ធកម្មរបស់ឈ្មោះ [redacted] សេងទ្រី តាំងពីឆ្នាំ២០០៥ ចំណែកឯការអះអាងអំពីការធ្វើលទ្ធកម្មដោយគ្មានមូលដ្ឋានច្បាប់របស់ឈ្មោះ [redacted] ភ័ន់ឌី នៅក្នុងឆ្នាំ២០១៥ ដែលមានគម្លាតរហូតដល់ទៅ១០ ឆ្នាំឯណោះ ហើយជាក់ស្តែងឈ្មោះ [redacted] សេងទ្រី ពុំបានធ្វើលទ្ធកម្មទៅកាន់តតិយជនឡើយតិតមកដល់បច្ចុប្បន្ន រីតតែមិនអាចជាបទល្មើសលួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ព្រោះថាអចលនវត្ថុនោះជាកម្មសិទ្ធិរបស់ខ្លួន ផ្អែកលើខ្លឹមសារនៃអង្គច្បាប់ខាងលើ។ បន្ថែមពីលើនេះទៀត កូនក្តីយើងខ្ញុំរងការចោទប្រកាន់បន្ថែមទៀតពី "បទប្រើប្រាស់ឯកសារសាធារណៈក្លែង" ផ្អែកតាមមាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌចែងថា ការប្រើប្រាស់ឯកសារក្លែងបន្លំប្រព្រឹត្តនៅក្នុងលិខិតយថាភូត ឬការប្រើប្រាស់ឯកសារក្លែងបន្លំប្រព្រឹត្តនៅក្នុងឯកសារដែលចេញដោយអ្នករាជការសាធារណៈ ដើម្បីធ្វើការកត់សម្គាល់សិទ្ធិ អត្តសញ្ញាណ ឬឋានៈ ឬដើម្បីយល់ព្រមផ្តល់ការអនុញ្ញាត ។ ផ្អែកតាមអង្គហេតុខាងលើបង្ហាញឱ្យឃើញថា កូនក្តីយើងខ្ញុំ ពុំបានប្រើប្រាស់ឯកសារក្លែងបន្លំឡើយ ព្រោះថាកូនក្តីយើងខ្ញុំជាដំបូងបានបង្កើតកិច្ចសន្យាលក់ទិញដែលជាលិខិតឯកជន បន្ទាប់មកក៏ទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋានដែលជាអ្នករាជការសាធារណៈ តាមរយៈពាក្យស្នើសុំកាន់កាប់ដីធ្លីលេខ ០៥/០៥ ឃ.ក.ផ ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ២០០៥ បានឃើញ និងបញ្ជាក់ដោយមេឃុំ

កណ្ដោក ដែលនេះជាការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋានអំពីនីត្យានុកូលនៃលិខិតឯកជនរបស់កូនក្ដីយើងខ្ញុំ ដើម្បីឱ្យកូនក្ដីយើងខ្ញុំយកឯកសារសាធារណៈ អំពីនីត្យានុកូលភាពនៃសិទ្ធិលើកម្មសិទ្ធិទៅសំអាង និងតតាំងជាមួយតតិយជនដែលមិនមែនជាការប្រើប្រាស់ឯកសារធារណៈក្លែងឡើយ។ ម្យ៉ាងវិញទៀត ចាប់តាំងពីពេលទិញដីពីឈ្មោះ[redacted]លាង និងប្រពន្ធឈ្មោះ [redacted] អាត នៅឆ្នាំ២០០៥ រួចមក កូនក្ដីយើងខ្ញុំឈ្មោះ [redacted] សេងទ្រី បានធ្វើការកាន់កាប់ដោយប្រយោល ស្របតាមមាត្រា២២៨ នៃក្រមរដ្ឋប្បវេណី ពោលគឺការកាន់កាប់តាមរយៈអ្នកដទៃ (ភតិសន្យា) ។ ក្នុងករណីនេះ ក៏មានការបំភ្លឺ អះអាងពីសាក្សី និងអាជ្ញាធរមូលដ្ឋានអំពីការកាន់កាប់ជាក់ស្ដែង ដោយការភ្ជាប់ទុកវត្ថុនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយនៃដំណាក់កាលអយ្យការ ដូចខាងក្រោម÷

-សាក្សីឈ្មោះ [redacted] ទូច (តាទូច) និងប្រពន្ធឈ្មោះ [redacted] សុវណ្ណ ជាអ្នកជួលដីពីឆ្នាំ២០០៥ រហូតដល់អំឡុងឆ្នាំ២០១៣-២០១៤ បានអះអាងពីការជួលប្រាកដមែន ជាអង្គហេតុមួយសបញ្ជាក់ថា កូនក្ដីយើងខ្ញុំពិតជាបានកាន់កាប់ និងអាស្រ័យផលពីពេលទិញរហូតមក។ ក៏ដូចជាមានការបំភ្លឺ ពីអ្នកយាមដីឈ្មោះ [redacted] ហ៊ុន ដែលបានមើលថែរក្សាបន្ទាប់ពីការឈប់ជួលដីនេះ។

-អតីតស្មៀនឃុំឈ្មោះ [redacted]រ៉ុម ជាអ្នកប្រថាប់ត្រាលើលិខិតទិញលក់ដីរវាងឈ្មោះ [redacted] លាង និងប្រពន្ធឈ្មោះ [redacted] អាត ដែលបានលក់ឲ្យកូនក្ដីយើងខ្ញុំ ដែលលោកបានបញ្ជាក់ពីការចុះហត្ថលេខាដោយលោក មេភូមិ និងមេឃុំចំពោះមុខគាត់។

-ការបំភ្លឺរបស់អ្នកជាប់ព្រំដីឈ្មោះ [redacted] ស៊ីផាត ហៅតាម៉ាប់ បានបញ្ជាក់ថាកូនក្ដីយើងខ្ញុំពិតជាបានទិញដីនេះតាំងពីឆ្នាំ២០០៥ មក ដោយបញ្ជាក់ពីការកាប់ឆ្ការព្រៃអូយ៉ាស់ និងការជួលដីជូនយាយ-តា ដូចបានរៀបរាប់ក្នុងអង្គហេតុខាងលើ។

លើសពីនេះទៀត តាមរយៈសេចក្ដីចម្លងរបាយការណ៍កោសលវិច័យ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១ របស់នាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្របានបញ្ជាក់ថា ស្នាមមេដៃរបស់ឈ្មោះ [redacted]លាង និងប្រពន្ធឈ្មោះ [redacted] អាត ជាស្នាមមេដៃតែមួយលើកិច្ចសន្យាលក់ផ្ដាច់ដីដែលលក់ឱ្យកូនក្ដីយើងខ្ញុំ។ ដោយឡែក ចំពោះលិខិតទិញ-លក់ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ១៩៩៧ រវាងអ្នកលក់ [redacted] ហោង, ឈ្មោះ [redacted] អាត) និងអ្នកទិញ ([redacted] ចាន់ហោង) វិញ ឈ្មោះ [redacted] អាត ត្រូវជាប្រពន្ធ[redacted]លាង បានឆ្លើយ និងបញ្ជាក់ក្នុងកំណត់ហេតុស្ដាប់ចម្លើយក្នុងដំណាក់កាលអយ្យការថា "ខ្លួនពុំបានផ្ដិតស្នាមមេដៃលក់ដីឲ្យក្រុមហ៊ុនរបស់ឈ្មោះ សៀង ចាន់ហោង ទេ ដោយថ្ងៃនោះរូបគាត់ជាប់កូនខ្ចីចេញពីផ្ទះមិនរួច តែនៅក្នុងលិខិតទិញ-លក់ដី បែរជាមានស្នាមមេដៃរបស់ឈ្មោះខ្លួន ([redacted] អាត) ទៅវិញ ការណ៍នេះបញ្ជាក់ពីភាពមិនប្រក្រតីនៃកិច្ចសន្យាទិញលក់នេះរបស់ភាគី [redacted] ចាន់ហោង "។

កូនក្ដីយើងខ្ញុំឈ្មោះ [redacted]សេងទ្រី មិនបានប្រើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិតឡើយ ព្រោះជាការកាប់ឆ្ការព្រៃអូយ៉ាស់លើដីរបស់ខ្លួន រីតតែមិនបានលួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួនទៅទៀត និងមិនបានប្រើប្រាស់ឯកសារសាធារណៈក្លែងឡើយ ព្រោះថាការប្រើប្រាស់ឯក

សាររបស់អាជ្ញាធរមូលដ្ឋានក្នុងការអះអាង និងតតាំងសិទ្ធិជាមួយតតិយជនដែលមករំលោភបំពាន គឺជាយន្តការនៃការប្រើប្រាស់សិទ្ធិស្របច្បាប់ ដែលត្រូវបានបញ្ជាក់ដោយឯកសាររបស់អាជ្ញាធរមូលដ្ឋានប៉ុណ្ណោះ មិនមែនជាការប្រើប្រាស់ឯកសារសាធារណៈក្លែងដូចការចោទប្រកាន់ឡើយ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] សេងទ្រី
- ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] លាង
- ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] អាត
- ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វ៉ាន់នី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សេងទ្រី
- ក្រោយពីបានពិនិត្យលើភស្តុតាងផ្សេងៗនៅក្នុងសំណុំរឿង
- ក្រោយពីបានពិនិត្យ និងពិភាក្សាក្នុងក្រុមប្រឹក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

**១.** យល់ឃើញថា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សេងទ្រី បានឆ្លើយថា÷ នៅក្នុងរឿងនេះ ខ្លួនមិនស្គាល់ឈ្មោះ [redacted] វ៉ាន់នី ឡើយ ហើយខ្លួនក៏មិនធ្លាប់មានទំនាស់ជាមួយគាត់ពីមុនមកដែរ។ ទើបតែពេលនេះតែប៉ុណ្ណោះដែលគាត់បានធ្វើការប្តឹងរូបខ្លួន ។ ក្នុងរឿងនេះ ខ្លួនបានទិញដីទំនាស់ខាងលើពីឈ្មោះ [redacted] លាង និងប្រពន្ធឈ្មោះ [redacted] អាត កាលពីអំឡុងឆ្នាំ២០០៥ ។ ពេលទិញលក់ដីខាងលើបានធ្វើកិច្ចសន្យាលក់ទិញត្រឹមត្រូវ មានការចូលរួមពីអាជ្ញាធរនៅក្នុងឆ្នាំ២០០៥ តែម្តង។ ក្រោយពីទិញដីខាងលើបានហើយ ខ្លួនបានជួលដីនោះឱ្យឈ្មោះ តាទូច ដើម្បីដាំដំណាំ (បន្លែ ននង ត្រសក់ ពោត សណ្តែក...) ។ ដីនោះមានបោះបង្គោលតាមព្រំចំនួន០៤(បួន) ដើម ។ ចាប់តាំងពីពេលទិញដីនោះ មិនធ្លាប់មានអ្នកណាមកអះអាងថាជាដីរបស់ខ្លួនទេ ទើបតែឆ្នាំ២០១៩ នេះទេដែលមានឈ្មោះ [redacted] វ៉ាន់នី មកប្តឹងតវ៉ា ។ ឯកសារទិញលក់ដីរបស់ខ្លួន គឺខ្លួន និងអ្នកលក់នាំគ្នាទៅសាលាឃុំដោយផ្ទាល់ ដើម្បីរៀបចំឯកសារនោះ។ លុះដល់ចុងឆ្នាំ២០១៩ ទើបឈ្មោះ [redacted] វ៉ាន់នី ប្តឹងរូបខ្លួន។ កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ពេលដែលខ្លួនទៅរៀបចំដីនោះ គឺមិនមានវត្តមានរបស់ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត ឡើយ។ ឃើញថា អំពើ និងសកម្មភាពរបស់ជនជាប់ចោទដែលបានចូលទៅទីតាំងដីខាងលើ និងបានរៀបចំសំអាតទីតាំងដីខាងលើ គឺធ្វើឡើងដោយសារតែខ្លួនគិតដីខាងលើគឺជារបស់ខ្លួន ដែលចំណុចនេះតប្បីតុលាការពិចារណាទៅលើចម្លើយសាក្សី, ឯកសារភស្តុតាងនានា និងសេចក្តីសន្និដ្ឋានផ្សេងៗរបស់សហមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងបីខាងលើ។

២. យល់ឃើញថា តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] លាង បានឆ្លើយថា÷ ខ្លួនមានដី០១ (មួយ) កន្លែងស្ថិតនៅភូមិពោម៉ា ឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលដីនេះមានទំហំបណ្ដោយ១៦២ ម៉ែត្រ ទទឹងទំហំ៥៣ ម៉ែត្រ ហើយមានព្រំប្រទល់ខាងត្បូងទល់នឹងឈ្មោះ [redacted] យ៉ាក ខាងកើតទល់នឹងឈ្មោះ [redacted] យ៉ាត ខាងលិចទល់ឈ្មោះ [redacted] លាស់, ឈ្មោះ [redacted] ថង និងដីរបស់ខ្លួនទៀត និងខាងជើងទល់នឹងឈ្មោះ សេម ។ ចំពោះដីនេះ គឺខ្លួនបានពីការកាប់ឆ្ការ រុករានដីព្រៃ ហើយក្រោយមកដីនេះខ្លួនបានដាំថ្នាំកាតាប និងបានដាំត្រាវ ពោត ឪឡឹក និងម្ទេសបន្ថែមទៀតនៅលើដីនេះ។ ក្រោយមកនៅក្នុងអំឡុងប្រហែលឆ្នាំ១៩៩២ ទៅឆ្នាំ១៩៩៣ ខ្លួនបានលក់ដីនេះទៅឱ្យក្រុមហ៊ុនឈ្មោះ សៀង ចាន់ហេង ក្នុងតម្លៃ ១,៦០០ $ (មួយម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក ហើយនៅពេលនោះខ្លួនបានទទួលប្រាក់កក់ចំនួន ៥០០,០០០ (ហាសិបម៉ឺន) រៀល ហើយពេលនោះខ្លួនបានផ្ដិតមេដៃលើកិច្ចសន្យាលក់ទិញដី និងលិខិតប្រគល់ទទួលប្រាក់កក់លើកទី១ ចំនួនដូចខាងលើ (ហាសិបម៉ឺនរៀល) ។ ប៉ុន្តែក្រោយមកក្រុមហ៊ុនឈ្មោះ សៀង ចាន់ហេង មិនបានប្រគល់ប្រាក់បង្គ្រប់ថ្លៃដីមកឱ្យខ្លួនទេ រហូតមកដល់ពេលបច្ចុប្បន្ន។ ចាប់តាំងពីឆ្នាំ២០១៨ មកខ្លួនមិនបានទៅធ្វើការបង្កបង្កើនផលទេ មូលហេតុដោយសារគេដឹកព្រៃកកាត់ មិនអាចឆ្លងគោយន្តទៅភ្ជួរបាន ប៉ុន្តែខ្លួននៅតែបន្តការកាន់កាប់ដដែល។ ចំពោះលិខិតលក់ទិញដីដែលបានធ្វើ នៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៧ នេះជាលិខិតដែលមានលក្ខណៈត្រឹមត្រូវពិតមែន។ ប៉ុន្តែពេលនោះប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] អាត មិនបានចូលរួមផ្ដិតមេដៃទេ។ ដោយឡែកឈ្មោះ [redacted] សុធី ខ្លួនមិនដែលស្គាល់ទេ ។ ខ្លួនមិនបានលក់ដីទៅឱ្យឈ្មោះ [redacted] សេងទ្រី ទេ ។ ចំពោះក្រយៅដៃលើកិច្ចសន្យាលក់ទិញផ្ទះផ្ដាច់ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ មានមេដៃ និងឈ្មោះរបស់ខ្លួននៅលើនោះគឺខ្លួនមិនបានផ្ដិតទេ។ សព្វថ្ងៃនេះខ្លួននៅតែកាន់កាប់ដីនេះដដែលមិនបានប្រគល់ឱ្យអ្នកណាឡើយ ដោយហេតុថា អ្នកទិញបានប្រគល់លុយកក់ឱ្យខ្លួនចំនួន ៥០០,០០០ (ហាសិបម៉ឺន) រៀល ក្នុងតម្លៃដីសរុបចំនួន ១,៦០០$ (មួយពាន់ប្រាំមួយរយ) ដុល្លារអាមេរិក។ បច្ចុប្បន្នខ្លួនមានបំណងឱ្យដើមបណ្ដឹងចូលមកដើម្បីផ្សះផ្សារ ដោយខ្លួនសូមសំណូមពរឱ្យដើមបណ្ដឹងកាត់ដីនេះទំហំក្បាល២០ ម៉ែត្រ និងបណ្ដោយទំហំ៣០ ម៉ែត្រ និងជំរើសទី២ គឺសូមឱ្យដើមបណ្ដឹងចេញជាប្រាក់ចំនួន ១០,០០០$ (មួយម៉ឺន) ដុល្លារអាមេរិក ។ ចម្លើយនេះ គប្បីតុលាការពិចារណាដោយធៀបជាមួយនឹងភស្តុតាងនានាក្នុងសំណុំរឿង។

៣. យល់ឃើញថា តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អាត បានឆ្លើយថា÷ ខ្លួនពិតជាមានដីមួយកន្លែងស្ថិតនៅភូមិពោម៉ា ឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលដីនេះមានបណ្ដោយទំហំ ១៦២ម៉ែត្រ និងទទឹងទំហំ ៥៣ម៉ែត្រ មានព្រំប្រទល់ខាងត្បូងទល់នឹងឈ្មោះ [redacted] យ៉ាក ខាងកើតទល់នឹងឈ្មោះ [redacted] យ៉ាក ខាងលិចទល់នឹងឈ្មោះ [redacted] លាស់ និងខាងជើងទល់នឹងឈ្មោះ សេម ។ ចំពោះដីនេះខ្លួនបានមកពីការកាប់ឆ្ការរុករានដីព្រៃ ហើយបានដាំដំណាំដូចជា ថ្នាំកាតាប ត្រាវ ពោត ឪឡឹក ម្ទេសបន្ថែមទៀតនៅលើដីនេះទៀតផង។ ក្រោយមកនៅក្នុងអំឡុងឆ្នាំ១៩៩២ ទៅឆ្នាំ១៩៩៣ ខ្លួន



Scanned with CamScanner

និងប្តីបានលក់ដីនេះទៅឱ្យក្រុមហ៊ុន សៀង ចាន់ហេង ក្នុងតម្លៃ១,៦០០(មួយពាន់ប្រាំមួយរយ) ដុល្លារអាមេរិក ប៉ុន្តែពេលទៅយកលុយកក់ដីនោះចំនួន ៥០០,០០០ (ហាសិបម៉ឺន) រៀល គឺខ្លួនមិនបានទៅយកលុយទេ គឺប្តីខ្លួនជាអ្នកទទួលផ្តិតមេដៃទទួលប្រាក់កក់ថ្លៃដីនោះចំនួន៥០០,០០០ (ហាសិបម៉ឺន) រៀល។ ក្រោយពេលកក់ប្រាក់ថ្លៃដីលើកទី១ហើយ ក្រុមហ៊ុន សៀង ចាន់ហេង មិនបានប្រគល់ប្រាក់ថ្លៃដីបង្គ្រប់មកឱ្យខ្លួន និងប្តីឡើយ ហើយដីនេះ ខ្លួន និងប្តីបានបន្តការកាន់កាប់អាស្រ័យផល រហូតមកដល់សព្វថ្ងៃនេះ។ ចំពោះ លិខិតលក់ទិញដីដែលបានធ្វើនៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៧ នេះ ខ្លួនមិនបានចូលរួមផ្តិតមេដៃទេគឺប្តីរបស់ខ្លួនជាអ្នកផ្តិតមេដៃ ព្រោះពេលនោះនាងខ្ញុំជាប់ឆ្លងទន្លេកូនខ្ចី។ ខ្លួនមិនបានលក់ដីឱ្យឈ្មោះ [redacted] សេងទ្រី នេះទេ។ សព្វថ្ងៃខ្លួននៅតែបន្តកាន់កាប់នៅលើដីនេះដដែល។ មូលហេតុដោយសារខាងក្រុមហ៊ុន សៀង ចាន់ហេង មិនទាន់បានទូទាត់ថ្លៃដីបង្គ្រប់មកឱ្យខ្លួន និងប្តីឡើយ។ បច្ចុប្បន្ននេះខ្លួនមានបំណងចង់ឱ្យដើមបណ្តឹងចូលមកដើម្បីធ្វើការផ្សះផ្សារ ដោយខ្លួនសូមសំណូមពរឱ្យដើមបណ្តឹងកាត់ដីនេះ ទំហំក្បាល២០ម៉ែត្រ និងបណ្តោយទំហំ ៣០ម៉ែត្រ និងជំរើសទី២ សូមឱ្យដើមបណ្តឹងចេញជាប្រាក់ចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក មកឱ្យខ្លួន និងប្តី ។ ខ្លួនសូមសំណូមពរដល់តុលាការមេត្តាកុំឃុំរឹបខ្លួនអី ព្រោះខ្លួនមានកូនក្នុងបន្ទុកចំនួន ០៤(បួន) នាក់ ត្រូវចិញ្ចឹម និងមានជំងឺគេងមិនលក់ថែមទៀតផង។ ចម្លើយនេះ តុលាការនឹងពិចារណាដោយធៀបទៅនឹងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ។

៤. យល់ឃើញថា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សេងទ្រី, ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត, លិខិតបញ្ជាក់ប្រវត្តិដីលេខ៥៦៧/២០ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅសង្កាត់រកាខ្ពស់ និងកិច្ចសន្យា ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៤ រវាងឈ្មោះ [redacted] ភឿន និងឈ្មោះ [redacted] លាង អាចបញ្ជាក់បានថា ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត ពិតជាម្ចាស់កម្មសិទ្ធិលើដីដែលមានបណ្តោយទំហំ ១៧០ ម៉ែត្រ និងទទឹងទំហំ ៥០ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិពោធិ៍ម៉ា ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រាកដមែន ។

៥. យល់ឃើញថា ផ្អែកតាមកិច្ចសន្យាលក់ផ្តាច់ដី ផ្ទះលេខ០៤/០៥ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ ២០០៥ រវាងឈ្មោះ [redacted] លាង, ឈ្មោះ [redacted] អាត និងឈ្មោះ [redacted] សេងទ្រី បានឃើញ និងបញ្ជាក់ដោយមេឃុំកណ្តោក អាចបញ្ជាក់បានថា ឈ្មោះ [redacted] លាង និងប្រពន្ធឈ្មោះ [redacted] អាត ពិតជាបានលក់ដី០១ (មួយ) កន្លែង មានបណ្តោយប្រវែង១៧០ ម៉ែត្រ និងទទឹងប្រវែង ៥០ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិពោធិ៍ម៉ា ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ឱ្យទៅឈ្មោះ [redacted] សេងទ្រី ដោយបានផ្តិតស្នាមមេដៃលើលិខិតនេះត្រឹមត្រូវ ដូចមានបញ្ជាក់ស្នាមមេដៃនៅក្នុងសេចក្តីចម្លងរបាយការណ៍កោសលវិច័យលេខ ០៣១/២១ ចល.របក/បវ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១ ប្រាកដមែន។ បន្ទាប់ពីឈ្មោះ [redacted] សេងទ្រី បានទិញដីពីឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត រួចហើយ ឈ្មោះ [redacted] សេងទ្រី បានបន្តការកាន់កាប់ និងប្រើប្រាស់ដីនោះរហូតមកដល់បច្ចុប្បន្ន។ ផ្អែកតាមខ្លឹមសារ និងភស្តុតាងនានាដែលមាននៅក្នុង

សេចក្ដីសន្និដ្ឋានការពារ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ របស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សេងទ្រី, ឈ្មោះ [redacted] លាង និងឈ្មោះ [redacted] អាត ដែលខ្លឹមសារ និងភស្តុតាងទាំងនេះដូចបានបញ្ជាក់នៅអង្គក្នុងសវនាការចំណុចទី៧ និងចំណុចទី៨ ។

៦. យល់ឃើញថា ផ្អែកតាមភស្តុតាងជាសាលដីការដ្ឋប្បវេណីលេខ០៥ក្រ IV.ខល ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ បានសម្រេចប្រគល់ដីដែលមានទំហំបណ្ដោយប្រវែង ១៧០ ម៉ែត្រ ទទឹងប្រវែង៥០ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិពោកម៉ា ឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលសព្វថ្ងៃប្ដូរមកជាភូមិទួលក្រសាំង សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្ដាល ដែលមានពាក្យស្នើសុំកាន់កាប់ដីធ្លីលេខ០៥/០៥ យកដ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៥ បានឃើញ និងបញ្ជាក់ដោយមេឃុំកណ្ដោក មកឱ្យឈ្មោះ [redacted] សេងទ្រី គ្រប់គ្រងជាកម្មសិទ្ធិ ។ ការសម្រេចសេចក្ដីនៅក្នុងសាលដីការដ្ឋប្បវេណីរបស់តុលាការជាន់ខ្ពស់នេះ អាចឱ្យតុលាការព្រហ្មទណ្ឌពិចារណាបានថា វិវាទ ឬទំនាស់រវាងដើមបណ្ដឹងរដ្ឋប្បវេណី និងជនជាប់ចោទ គឺជាវិវាទផ្នែករដ្ឋប្បវេណីអំពីភាពជាកម្មសិទ្ធិករ ឬអតិភាពនៃសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដែលការសម្រេចនេះមិនទាន់ចូលជាស្ថាពរនៅឡើយ ។

៧. យល់ឃើញថា តាមរយៈសំអាងហេតុត្រង់ចំណុចទី១ រហូតដល់ចំណុចទី៦ ខាងលើ បានបញ្ជាក់ថា ឈ្មោះ [redacted] សេងទ្រី ពិតជាបានកាន់កាប់ និងប្រើប្រាស់ដីធ្លីខាងលើក្នុងនាមជាម្ចាស់កម្មសិទ្ធិលើដីទំហំបណ្ដោយប្រវែង១៧០ ម៉ែត្រ ទទឹងប្រវែង៥០ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិពោកម៉ា ឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលសព្វថ្ងៃប្ដូរមកជាភូមិទួលក្រសាំង សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្ដាល ដែលមានពាក្យស្នើសុំកាន់កាប់ដីធ្លីលេខ០៥/០៥ យកដ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៥ បានឃើញ និងបញ្ជាក់ដោយមេឃុំកណ្ដោកឈ្មោះ [redacted] មឿន ប្រាកដមែន ដែលអំពើនេះ មិនមែនជាបទល្មើសព្រហ្មទណ្ឌដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ ហេតុដូច្នេះ គប្បីតុលាការសម្រេចឱ្យជនចាប់ចោទរួចខ្លួនពីបទចោទប្រកាន់ ។

៨. យល់ឃើញថា ពុំមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] សេងទ្រី ភេទប្រុស, ឈ្មោះ [redacted] លាង ភេទប្រុស និងឈ្មោះ [redacted] អាត ភេទស្រី ពីបទ÷ ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន និងប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅភូមិអំពៅព្រៃ ឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីអំឡុងឆ្នាំ ២០២០ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា២៥៣ និងមាត្រា២៥៥ នៃច្បាប់ភូមិបាល និងមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ឡើយ។ ហេតុដូច្នេះ គប្បីឱ្យជនជាប់ចោទឈ្មោះ [redacted] សេងទ្រី ភេទប្រុស, ឈ្មោះ [redacted] លាង ភេទប្រុស និងឈ្មោះ [redacted] អាត ភេទស្រី រួចខ្លួនពីបទចោទតាមបញ្ញត្តិមាត្រា៣៥០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ សម្រេចសេចក្តី

១. ឱ្យឈ្មោះ[redacted]លាង ភេទប្រុស អាយុ៥៦ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted]អាត ភេទស្រី អាយុ៥៤ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] សេងទ្រី ភេទប្រុស អាយុ៥៤ឆ្នាំ ជនជាតិខ្មែរ រួចខ្លួនពីបទ÷ ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន និងប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅភូមិអំពៅព្រៃ ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា២៥៣ និងមាត្រា២៥៥ នៃច្បាប់ភូមិបាល និងមាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ តាមបញ្ញត្តិមាត្រា៣៥០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សេងទ្រី, ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វ៉ាន់ឌី និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted]លាង និងឈ្មោះ [redacted]អាត តែចាត់ទុកចំពោះមុខ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** ចៅក្រមជំនុំជម្រះ

**ហត្ថលេខា និងត្រា÷** [redacted] ហត្ថលេខា និងត្រា÷ [redacted]

---

**បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ ២កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តកណ្តាល, ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]